ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

*ថ្ងៃចន្ទ ១១កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៦*

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន ១៤៦ ដែលមានទុនវិនិយោគសរុបប្រមាណ ២,៥ប៊ីលានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីនៅកម្ពុជា ក្នុងត្រីមាសទី១ ឆ្នាំ២០២៦

ក្នុងត្រីមាសទី១ ឆ្នាំ២០២៦ គម្រោងវិនិយោគសរុបដែលត្រូវបានចុះបញ្ជីនៅកម្ពុជា ទាំងការចុះបញ្ជីដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) ទាំងការចុះបញ្ជីដោយអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត (អ.គ.វ.រ.ខ.) មានចំនួន ១៤៦គម្រោង ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ២,៥ប៊ីលានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានប្រមាណ ៨២ពាន់កន្លែង។ ក្នុងចំណោមគម្រោងវិនិយោគទាំង ១៤៦នេះ មានគម្រោងចំនួន ៩៥ ត្រូវបានចុះបញ្ជីដោយ ក.អ.ក. (ក្រៅតំបន់សេដ្ឋកិច្ចពិសេសចំនួន ៦០គម្រោង និងក្នុងតំបន់សេដ្ឋកិច្ចពិសេសចំនួន ៣៥គម្រោង) និងគម្រោងចំនួន ៥១ ត្រូវបានចុះបញ្ជីដោយ អ.គ.វ.រ.ខ.។

ក្នុងត្រីមាសទី១ ឆ្នាំ២០២៦នេះ កម្ពុជានៅតែអាចទាក់ទាញគម្រោងវិនិយោគធំៗ ដូចជាគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស, គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់, គម្រោងវិនិយោគបង្កើតរោងចក្រផ្គុំដំឡើងរថយន្ត, ផ្គុំដំឡើងម៉ូតូ, និងផលិតសំបកកង់រថយន្ត ដូចមានគូសរំលេចក្នុងចំណុចគម្រោងលេចធ្លោខាងក្រោម។ វត្តមាននៃគម្រោងវិនិយោគទាំងនេះ នឹងជួយឆ្លុះបញ្ចាំងពីភាពល្អប្រសើរនៃបរិស្ថានវិនិយោគនៅកម្ពុជា ដែលរាជរដ្ឋាភិបាលបាននិងកំពុងដាក់ចេញនូវវិធានការជាបន្តបន្ទាប់ដើម្បីឆ្លើយតបនឹងបញ្ហាវិបត្តិសកលដែលបានជះឥទ្ធិពលមកលើកម្ពុជា សំដៅថែទាំវិនិយោគដែលមានស្រាប់ និងជំរុញទាក់ទាញវិនិយោគថ្មី ពិសេសលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា។

គម្រោងវិនិយោគដែលមានភាពលេចធ្លោជាងគេប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ រួមមាន៖

### ក. ក្រៅតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| កសិកម្ម និង កសិ-ឧស្សាហកម្ម | **គម្រោងពង្រីកផលិតកម្ម និងបន្ថែមអគាររោងចក្រកែច្នៃផ្លែស្វាយ គ្រាប់ស្វាយចន្ទី ចេក ខ្នុរ...**<br>- **ទីតាំង៖** ខេត្តកំពង់ស្ពឺ<br>- **ទុនវិនិយោគបន្ថែម៖** ប្រមាណ១៤លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ២.២០១កន្លែង។ |
| ឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រផលិតមី និងគ្រឿងផ្សំសម្រាប់មី**<br>- **ទីតាំង៖** ខេត្តកំពង់ស្ពឺ<br>- **ទុនវិនិយោគ៖** ប្រមាណ ២៣លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ៨០៤កន្លែង។ |

| | |
|---|---|
| ឧស្សាហកម្ម | **គម្រោងវិនិយោគផ្គុំដំឡើងរថយន្ត**<br>- **ទីតាំង៖** ខេត្តកណ្ដាល<br>- **ទុនវិនិយោគ៖** ប្រមាណ១១លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ១៦០កន្លែង។<br>**គម្រោងវិនិយោគបង្កើតរោងចក្រផ្គុំដំឡើងម៉ូតូ**<br>- **ទីតាំង៖** រាជធានីភ្នំពេញ<br>- **ទុនវិនិយោគ៖** ប្រមាណ ៨លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ២៨៤កន្លែង។<br>**គម្រោងវិនិយោគបង្កើតរោងចក្រផលិតត្រីខកំប៉ុង និងទឹកត្រី**<br>- **ទីតាំង៖** ខេត្តកែប<br>- **ទុនវិនិយោគ៖** ប្រមាណ ៧លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ១៧១កន្លែង។ |
| ទេសចរណ៍ | **គម្រោងវិនិយោគសាងសង់ និងធ្វើអាជីវកម្មសណ្ឋាគារថ្នាក់ផ្កាយ៥ ចំនួន១.៣៤១បន្ទប់**<br>- **ទីតាំង៖** ខេត្តស្វាយរៀង<br>- **ទុនវិនិយោគ៖** ៣០០លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ២.០៦០កន្លែង។ |
| ហេដ្ឋារចនាសម្ព័ន្ធ | **គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់អនុភាព១៥០មេហ្គាវ៉ាត់**<br>- **ទីតាំង៖** ខេត្តមណ្ឌលគិរី<br>- **ទុនវិនិយោគ៖** ប្រមាណ ២០០លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ៤២កន្លែង។ |

## ខ. ក្នុងតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| ឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រផលិតសំបកកង់រថយន្ត និងពោះវៀនកង់**<br>- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស **យូ ប៊ី អ៊ី ស្ដួល** នៅខេត្តក្រចេះ<br>- **ទុនវិនិយោគ៖** ៤៥០លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ៣.៥២៨កន្លែង។<br>**គម្រោងវិនិយោគបង្កើតរោងចក្រផ្គុំ និងដំឡើងរថយន្តអគ្គិសនី "EV"**<br>- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស **ពោធិ៍សាត់** នៅខេត្តពោធិ៍សាត់<br>- **ទុនវិនិយោគ៖** ៤៦លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ៦១១កន្លែង។ |
| ហេដ្ឋារចនាសម្ព័ន្ធ | **គម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន៤តំបន់**<br>- **ទីតាំង៖** ខេត្តកំពង់ស្ពឺចំនួន ២តំបន់ និងកំពតចំនួន ២តំបន់<br>- **ទុនវិនិយោគ៖** ៦៣៥លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ១.២៨៦កន្លែង។ |

# គម្រោងវិនិយោគក្នុង ត្រីមាសទី១ ឆ្នាំ២០២៦

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

ដែលត្រូវបានអនុម័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា

**គម្រោងវិនិយោគ**
**១៥៦**
គម្រោង

**ទុនវិនិយោគ**
**២,៥** ប៊ីលាន
ដុល្លារអាម៉េរិក

**បង្កើតការងារ**
**~៨២៣ន់**
កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)




## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| ១. ចិន | ៤៦,៧៧% |
| ២. កម្ពុជា | ៣៨,០៦% |
| ៣. ម៉ាឡេស៊ី | ៨,១៤% |
| ៤. សិង្ហបុរី | ៤,៦៥% |
| ៥. កោះ British Virgin | ០,៦៩% |
| ៦. សហរដ្ឋអាម៉េរិក | ០,៣៣% |
| ៧. អេមីរ៉ាតអារ៉ាប់រួម | ០,៣២% |
| ៨. សីស្ហែល | ០,២៨% |
| ៩. កោះ Samoa | ០,២៣% |
| ១០. សាធារណរដ្ឋកូរ៉េ | ០,២២% |

## របាយគម្រោងវិនិយោគនៅតាមបណ្តារាជធានី-ខេត្ត

